# ទិដ្ឋភាពមួយចំនួននៃទស្សនវិជ្ជាខ្មែរ

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ទស្សនវិជ្ជាខ្មែរបានកើតឡើងក្នុងសង្គមខ្មែរតាំងពីយូរលង់ណាស់មកហើយ ពោលគឺតាំងពីសម័យកាលបុរេប្រវត្តិសាស្ត្រមកម្ល៉េះ ហើយមានការរីកចម្រើនខ្លាំងនៅដើមដំបូងនៃសម័យប្រវត្តិសាស្ត្រ ជាពិសេសក្នុងសម័យអង្គរ។ ទស្សនវិជ្ជាខ្មែរបានកប់ទុកក្នុងសិលាចារឹកនានា ក្នុងអក្សរសិល្ប៍ សិល្បៈ ទំនៀមទម្លាប់ ប្រពៃណី សុភាសិត កំណាព្យ និងជំនឿផ្សេងៗ ដែលបញ្ជាក់ឱ្យឃើញថាខ្មែរមានទស្សនវិជ្ជាជ្រៅជ្រះរបស់ខ្លួនក្នុងការរួមចំណែកអភិវឌ្ឍ និងការពារប្រទេសជាតិ។*

## ១-ទស្សនវិជ្ជាខ្មែរតាមរយៈសិលាចារឹក

*សិលាចារឹកវ៉ូកាញ់ដែលជាសិលាចារឹកខ្មែរដំបូង ហើយមានចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍ ទំនងជាត្រូវបានគេសរសេរនៅសតវត្សរ៍ទី២ឬទី៣ កត់ត្រាជាភាសាសំស្ក្រឹតថ្លែងពីព្រះបាទស្រីមារៈ (ហ្វាន់ ចេម៉ាន់) ទ្រង់មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា។*[1]

*អត្ថបទសិលាចារឹកនេះក៏បានបញ្ជាក់អំពីចិត្តសន្តោសរបស់ព្រះមហាក្សត្រមួយអង្គដែលគិតគូរដល់សុភមង្គលរបស់ប្រជារាស្ត្រ ដោយព្រះអង្គបានធ្វើបទបញ្ញាទុកឱ្យមហាក្សត្រតៗមកប្រតិបត្តិតាម។ សិលាចារឹកមួយនៅប្រាសាទគោករកា* (K. 435) *នៅសម័យអង្គររៀបរាប់ពីព្រះបាទជ័យវរ្ម័នទី៧ ដែលទ្រង់មានព្រះរាជបន្ទូលថា "ជំងឺរបស់ប្រជារាស្ត្រ ធ្វើឱ្យព្រះអង្គឈឺចាប់ជាងជំងឺផ្ទាល់របស់ព្រះអង្គ"។*[2]

*សិលាចារឹកខ្លះទៀតមានរៀបរាប់អំពីប្រវត្តិសាស្ត្រ សាសនា ប្រាសាទ ទំនៀមទម្លាប់ កិត្តិនាមវរជនជាមេទ័ព សេចក្តីរំភើបចិត្តក្នុង*

---

[1] *ត្រឹង ង៉ាៈ* ***អរិយធម៌ខ្មែរ*** *ការផ្សាយរបស់អ្នកនិពន្ធ គ.ស. ១៩៧៥*

[2] *ជា គឹមនេង និង ហ៊ិន សំអាតៈ* ***រដ្ឋបាលសាធារណៈ*** *ឆ្នាំ២០២១*

ជ័យជម្នះ និងការរៀបចំជីវភាពសង្គម[៣]។

## ២-ទស្សនវិជ្ជាខ្មែរតាមរយៈសុភាសិត

### -«**ចេះឯងឱ្យក្រែងចេះគេ**»

«**ចេះឯងឱ្យក្រែងចេះគេ**» មានន័យថា ទោះបីជាយើងមានចំណេះដឹង បទពិសោធន៍ វិធី ល្បិច ទេពកោសល្យ កម្លាំង និងបញ្ញាខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏យើងមិនត្រូវធ្វេសប្រហែស ឬប្រមាទដៃគូប្រកួត ឬសត្រូវរបស់យើងដែរ។ ប្រសិនបើយើងប្រមាទចំពោះដៃគូប្រកួតប្រជែងឬសត្រូវរបស់យើង នោះយើងអាចចាញ់ល្បិចរបស់គេ និងអាចបរាជ័យជាយថាហេតុ ពីព្រោះថា ទោះបីជាយើងមានទស្សនវិជ្ជាខ្ពស់ មានចិត្តសាស្ត្រជ្រៅជ្រះ មានការវាយតម្លៃប្រកបដោយគតិបណ្ឌិតក៏ដោយ ក៏យើងមិនអាចព្យាករណ៍ និងវាយតម្លៃសមត្ថភាព លទ្ធភាព និងសក្តានុពលរបស់ដៃគូប្រកួតប្រជែង ឬសត្រូវរបស់យើងបានគ្រប់ជ្រុងជ្រោយមួយរយភាគរយដែរ។ ហេតុនេះ មានតែការចេះប្រមាណ ចេះក្រែង និងចេះប្រយ័ត្ន ដែលជាផ្លូវកណ្តាលនេះទេ ទើបអាចធ្វើឱ្យយើងទទួលបានជោគជ័យសមតាមសេចក្តីប្រាថ្នារបស់យើង។

### -«**ត្រីមួយត្រក ស្អុយមួយ ស្អុយទាំងអស់**»

សុភាសិត«**ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់**» កើតមាននៅក្នុងសង្គមខ្មែរតាំងពីយូរលង់មកហើយ។ សមាជិកសង្គមខ្មែរបានយល់ដឹងអត្ថន័យរបស់វាស្ទើរតែគ្រប់គ្នា ដូចជាក្នុងករណីសមាជិកម្នាក់របស់ក្រុមណាមួយ គ្រួសារណាមួយ ឬស្ថាប័នណាមួយ ប្រព្រឹត្តខុស គេក៏និយាយថាក្រុមនោះគ្រួសារនោះ ឬស្ថាប័ននោះ ប្រព្រឹត្តខុសទាំងអស់។

ការពិចារណាបែបនេះ គឺជាទម្រង់នៃការពិចារណាដែលវាមិនអាចឈានទៅដល់សច្ចភាពដាច់ខាតឬខ្ពស់បំផុតបានទេ និងផ្ទុយទៅវិញវាងាយនឹងខុសបំផុត។ ប្រសិនបើបុគ្គលណាម្នាក់ឬសមាជិកណាម្នាក់បានប្រព្រឹត្តខុស គួរដាក់ទោសតែអ្នកនោះបានហើយ មិនគួរចាត់វិធានការណាមួយដែលនាំឱ្យខូចកេរ្តិ៍ឈ្មោះ និងបាត់បង់ផលប្រយោជន៍របស់ក្រុមគ្រួសារ ស្ថាប័ន និង អ្នកដទៃដែលមិនបានប្រព្រឹត្តខុសនោះទេ។ ប្រសិនបើអ្នកដែលមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្ត ប្រើប្រាស់តួនាទី សិទ្ធិ និងឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចអ្វីមួយ ដោយផ្អែកលើគំនិតនៃសុភាសិត «ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់» នោះនាំឱ្យអ្នកដែលទទួលផលប៉ះពាល់ពីសេចក្តីសម្រេចចិត្តនេះ នឹងទទួលរងគ្រោះដោយខូចកេរ្តិ៍ឈ្មោះ បាត់បង់នូវផលប្រយោជន៍ និងទទួលរងនូវភាពអយុត្តិធម៌ផ្សេងៗ[៤]។

---

[៣] សូមអាន ឡុង សៀម «*ស្ថាននាមវិទ្យាខ្មែរ Toponymie Khmer*» ពុទ្ធសាសនបណ្ឌិត្យ ១៩៩៧។

[៤] ឃេត ប៊ុនថង៖ ***ទស្សនវិជ្ជាខ្មែរតាមរយៈសុភាសិត*** ភាគទី១ ឆ្នាំ២០២២

-«***ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី***»

ជាធម្មតា នៅក្នុងសង្គម ជោគជ័យ បរាជ័យ ឬវាសនារបស់មនុស្ស តែងតែឡើងចុះ ឬប្រែប្រួលទៅតាមកាលៈទេសៈ ស្ថានភាព និងលក្ខខណ្ឌចាំបាច់មួយចំនួន។ ម្តងអ្នកនេះជោគជ័យ ម្តងអ្នកនោះជោគជ័យ ពេលខ្លះអ្នកនេះខ្លាំង ពេលខ្លះអ្នកនោះខ្លាំង ពេលខ្លះអ្នកនេះមាន ពេលខ្លះអ្នកនោះមាន សម័យមុនក្រុមនោះធ្វើធំ សម័យនេះក្រុមនេះធ្វើធំ។

នៅក្នុងតថភាពសង្គម គេសង្កេតឃើញក្នុងករណីខ្លះ អ្នកខ្លាំង អ្នកជោគជ័យ អ្នកមាន អ្នកកាន់អំណាចក្នុងសម័យកាលមួយ បានធ្វើបាប គាបសង្កត់ បង្ក្រាប និងកេងចំណេញលើអ្នកខ្សោយ អ្នកបរាជ័យ អ្នកក្រ និងអ្នកគ្មានអំណាច។ ផ្ទុយទៅវិញ ពេលដែលពួកគេចុះខ្សោយ និងបាត់បង់អំណាចវិញ ពួកគេក៏ត្រូវក្រុមដែលធ្លាប់ទទួលរងគ្រោះពីមុននោះធ្វើបាបឬសងសឹកវិញដែរ។

សុភាសិតនេះបានបង្កប់គំនិតអប់រំមួយយ៉ាងសំខាន់ ដោយអប់រំកូនខ្មែរកុំឱ្យចងពៀរ កុំឱ្យ សងសឹក និងចងអាឃាតគ្នា ពីព្រោះការសងសឹកគ្នាទៅវិញទៅមកនេះ មិនអាចដោះស្រាយបញ្ហាបានទេ ហើយវាក៏គ្មានទីបំផុតដែរ។ តាមពិតទៅ អ្នកមានអំណាចនិងអ្នកគ្មានអំណាច អ្នកមានទ្រព្យនិងអ្នកក្រទ្រព្យ អ្នកខ្លាំងនិងអ្នកខ្សោយ មិនគួរយកគ្នាជាសត្រូវនោះទេ ពួកគេគួរតែចាត់ទុកគ្នាជាដៃគូសហការគ្នាទៅវិញទៅមក និងជួយគ្នាទៅវិញទៅមក។ ក្នុងករណីដែលពួកគេមានជម្លោះឬបញ្ហាជាមួយគ្នា ពួកគេគួរតែព្យាយាមអត់ឱនគ្នា អធ្យាស្រ័យឱ្យគ្នា និងអាចដោះស្រាយដោយសន្តិវិធី តាមផ្លូវសីលធម៌ ឬច្បាប់ ជាជាងការសងសឹកគ្នាទៅវិញទៅមក។

-«***ផឹកទឹកឱ្យនឹកដល់ប្រភព ជ្រកម្លប់ឱ្យនឹកដល់អ្នកដាំ***»

«***ផឹកទឹកឱ្យនឹកដល់ប្រភព ជ្រកម្លប់ឱ្យនឹកដល់អ្នកដាំ***» បង្កប់នូវវប្បធម៌ដឹងគុណដ៏ជ្រាលជ្រៅ ដែលជំរុញនិងលើកទឹកចិត្តឱ្យសង្គមខ្មែរក៏ដូចជាសង្គមមនុស្សទូទៅស្វែងរកនិងស្វែងយល់ពីប្រភពដែលបង្កើតឱ្យមានផលល្អ គោរពនិងដឹងគុណដល់អ្នកដែលបានបង្កើតឱ្យមានសមិទ្ធផលឬស្នាដៃ អ្នកកសាង អ្នកដែលបានជួយសង្គ្រោះ និងអ្នកផ្តល់ជំនួយ ជាដើម។ លើសពីនេះ សុភាសិតនេះក៏ចង់ឱ្យអ្នកជំនាន់ក្រោយ ឬអ្នកដែលបានទទួលផលពីបុព្វការី ចេះដកស្រង់បទពិសោធន៍ បន្តវេន ផ្តល់កិត្តិយស និងអាចតបស្នងតាមលទ្ធភាពដែលអាចធ្វើទៅបាន។

-«***ចង់ចេះឱ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឱ្យយកភ្លើងដុតគល់***»

«***ចង់ចេះឱ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កា ឱ្យយកភ្លើងដុតគល់***» មានបង្កប់នូវគំនិតទស្សនវិជ្ជាដ៏ល្អប្រពៃដែលមិនអាចកាត់

ថ្ងៃបាន ពីព្រោះវាបានប្រាប់យើងពីគំនិតនិងវិធីដែលអាចសម្ងាប់ចិត្តរបស់អាចារ្យ ឬគ្រូដើម្បីឱ្យគាត់សុខចិត្តលះបង់ទាំងកម្លាំងកាយកម្លាំងចិត្ត ពេលវេលា និងព្រមបង្រៀនអ្វីៗទាំងអស់ដែលគាត់ចេះមកដល់យើង ព្រមទាំងបង្ហាញពីវិធីដែលនាំឱ្យយើងទទួលបានជោគជ័យ ផ្លែផ្កា ឬលទ្ធផលល្អ ជាពិសេសជួយឱ្យយើងគេចផុតពីឧបសគ្គ ហានិភ័យ និងកម្លាំងអូសទាញបែបអវិជ្ជមានដែលអាចនាំយើងឱ្យអន្តរាយ ខាតបង់ផលប្រយោជន៍ ឬបរាជ័យជាយថាហេតុ។

-«**ចេះមកពីរៀន មានមកពីរក**»

ការមករៀនក្នុងថ្នាក់ ការអានសៀវភៅ ឬឯកសារផ្សេងៗ ការស្ដាប់វិទ្យុឬការពិភាក្សា ការទស្សនាកម្មវិធីនានាក្នុងទូរទស្សន៍ វីដេអូ ឯកសារស្រាវជ្រាវក្នុងប្រព័ន្ធបណ្ដាញសង្គមៗលៗ រួមទាំងការចូលរួមក្នុងវេទិកាផ្សេងៗ ក៏សុទ្ធសឹងជាមធ្យោបាយនៃការរៀន។ ជាទូទៅ ការរៀនទាំងនេះ តែងតែផ្ដល់ចំណេះដឹងដល់អ្នករៀន ទោះបីតិចឬច្រើនក៏ដោយ គ្មាននរណាម្នាក់ដែលបានឆ្លងកាត់ការរៀនហើយមិនបានទទួលចំណេះដឹងអ្វីសោះនោះទេ។ អ្នកដែលមិនបានឆ្លងកាត់ការរៀនសូត្រ គឺប្រាកដណាស់ថា ពួកគេពិតជាមិនអាចទទួលបានចំណេះដឹងឡើយ។ បើចង់មានទ្រព្យ ទទួលបានទ្រព្យ ឬចង់ក្លាយទៅជាអ្នកមាន មហាសេដ្ឋី ជាដើម ត្រូវតែខិតខំរកស៊ី ធ្វើការតាមលទ្ធភាព សមត្ថភាព និងទេពកោសល្យរបស់ខ្លួន។ បើមិនដូចច្នោះទេ ពួកគេមិនអាចទទួលបានទ្រព្យឡើយ។ អ្វីៗទាំងអស់តែងតែប្រព្រឹត្តទៅតាមទំនាក់ទំនងរវាងហេតុនិងផល។ គ្មានអ្វីមួយដែលកើតឡើងដោយឯកឯងនោះទេ។ ក្នុងសុភាសិត ខាងលើ ចេះគឺជាផល រៀនគឺជាហេតុ មានគឺជាផល ឯរកគឺហេតុ។ ជាការពិតណាស់ គ្មានមនុស្សណាម្នាក់ដែលនៅសម្ងំស្ងៀមឬខ្ជិលមិនធ្វើអ្វីសោះហើយបែរជាទទួលបានចំណេះដឹងឬទ្រព្យសម្បត្តិនោះទេ។

នៅក្នុងសុភាសិតនេះ បុព្វបុរសខ្មែរចង់អប់រំកូនខ្មែរឱ្យស្គាល់ពីទំនាក់ទំនងរវាងហេតុនិងផល កុំឱ្យចេះតែពឹងលើព្រេងសំណាងឬព្រហ្មលិខិត តែត្រូវជឿលើហេតុផល ពឹងលើសមត្ថភាព ការឧស្សាហ៍ព្យាយាម និងការប្រឹងប្រែងរបស់ខ្លួន។ ជាការណ៍ពិតក្នុងតថភាពធម្មជាតិ ពួកខ្លា តោ ឬសិង្ហ ជាដើម ទាល់តែវាខិតខំដេញចាប់សត្វម្រឹគ ទើបពួកវាអាចបានម្រឹគទាំងនោះមកធ្វើជាចំណី មិនមែននៅសម្ងំស្ងៀមមួយកន្លែង ហើយម្រឹគទាំងនោះរត់មកចូលមាត់របស់ពួកវានោះទេ។

## ៣-ទស្សនវិជ្ជាខ្មែរតាមរយៈកំណាព្យ

### -ច្បាប់ពាក្យចាស់

ពាក្យចាស់ពាក្យពីព្រេង
ទោសខ្លួនឯងមើលពុំយល់

ទោសគេតូចសោតសល់
រមិលយល់ប៉ុនទាំងភ្នំ។
ចូលព្រៃសត្វសាហាវ
រកអំពាវគ្នាមកជុំ
ដល់បានស្គរទឹកឃ្មុំ
ពួនក្នុងផ្ទះធំម្នាក់ឯង។
បានហើយចង់បានទៀត
ធ្មៀតហើយធ្មៀតពុំគិតឈ្វេង
មើលយល់តែម្នាក់ឯង
មិនយល់គេឯទៀតផង។[5]

**-ច្បាប់ព្រះរាជសម្ភារ**

ខ្វែងហើរត្បិតខ្យល់ នាយថ្កើងត្បិតពល
រក្សាឱ្យសុខ ទ្រព្យគង់ត្បិតស្រី ចេះសំចៃទុក
ផ្ទះធំស្រណុក ត្បិតកិរិយាជា។
បាត់យសត្បិតខ្ជិល បាត់ញាណទានសីល
ត្បិតសេពសុរា ប្រមាថបាត់បុណ្យ
ខឹងបាត់ប្រាជ្ញា លេញលេងដៀលថា
បាត់កិរិយាគាប់។
អត់ឱនឥតទោស ធ្វើចិត្តសន្តោស
បង្កើតជាទ្រព្យ មេត្រីជាញាតិ រក្សាដល់ស្លាប់
ចៀសក្តីពុំគាប់ ជាគន្ធពិដោរ។[6]

**-ច្បាប់ល្បើកថ្មី**

បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន
ឱ្យមាំឱ្យស្ទាត់ កុំចេះស្ទាក់ស្ទើរ ល្បីល្បើឥតបទ
បើចេះប្រាកដ ប្រាក់រត់តាមហៅ។
កុំថ្នមកម្លាំង កាប់ដីកចូកចាំង កុំថារង៉ាក្តៅ
រៀនអ្វីឱ្យធ្លិន កុំឱ្យខ្លោចឆៅ កុំដេកតែខ្ជៅ
ក្រក្រៅសណ្តាប់។
បើល្ងង់ឱ្យចេះ រករៀនតម្រិះ រិះរកតម្រាប់
ឥន្ទ្រិយឆ្ងេងស្តាំ កុំចាំគេប្រាប់ រៀនស្តីរៀន
ស្តាប់ រៀនមើលឱ្យស្តែង។[7]

**-ច្បាប់ស្រី**

មួយល្អរូបសសន្ទាង ឥតគេផ្ទឹមខាង ច្បាប់ផង
មិនចេះ ល្អពិតគំនិតមិនផេះ ទោះខ្មៅក្រផេះ
ការសោតសមគួរ។
គឺមោះនាងនោះមិនជួ ចេះដឹងសមគួរ ស្គាល់
អស់តរិយា។
នេះឯងពីព្រេងលោកថា ហៅល្អរូបា
កបកល្យាណី។

**-ច្បាប់ប្រុស**

រៀនបទរៀនបាទចាស
កុំច្រឡាសលើរៀមច្បង
ស្រដីនឹងអ្នកផង
ពាក្យឱ្យគួរកុំឯងរ៉ឺ។
អឺអើអញដាច់សាច់
ធ្លងពាក្យពេចន៍គេស្រដី

---

[5] សមាគម សម្តេច ជួន ណាតៈ *ច្បាប់ផ្សេងៗ* ភ្នំពេញ ព. ស. ២៥១៨

[6] សមាគម សម្តេច ជួន ណាត ៖ *ច្បាប់ផ្សេងៗ* ដ.ឯ.ម.

[7] អ្នកព្រះកិរម្យកាសា អ៊ូ ហៅ ង៉ុយៈ *បណ្តាំក្រមង៉ុយ* ការផ្សាយរបស់អង្គការសន្តិស៊ុគ្រចិត្តកម្ពុជា គ. ស. ២០០៥

ដើមដៀលឱ្យអប្រិយ
ស្រដីថាកូនអត់ពូជ។
ចាស់ទុំមិនប្រដៅ
ដេរកូនចៅទើបវាខូច
គេថាកូនឥតពូជ
មិនដឹងច្បាប់និងចាស់ទុំ។
គេដៀលដល់ម៉ែឪ
កេរ្តិ៍អាស្រូវស្អុយរហ៊ុំ
គេស្តីដើមជៀវជុំ
ដំនៀលនោះដល់មកចាស់។[៨]

**៤-ទស្សនវិជ្ជាខ្មែរតាមរយៈជំនឿ**

ជំនឿគឺជាកត្តាជុំរុញឱ្យព្រលឹងឬអារម្មណ៍របស់មនុស្សជឿថាមានព្រះឬវត្ថុស័ក្តិសិទ្ធិជាអ្នកផ្តល់ក្តីសង្ឃឹម ធ្វើឱ្យស្មារតីមនុស្សកាន់តែល្អប្រសើរ មានភាពស្មោះត្រង់ មានសមត្ថភាព ឆន្ទៈ ការទទួលខុសត្រូវនិងការសន្តោសប្រណី។

នាបុព្វសម័យខ្មែរមានជំនឿហើយ។ ជំនឿទាំងនោះជាមធ្យោបាយធ្វើឱ្យខ្មែរមានសាមគ្គីធម៌រវាងគ្នា ព្រោះថាកាលបើគេមានជំនឿដូចគ្នា ការប្រាស្រ័យទាក់ទងក៏មានភាពស្និទ្ធស្នាល ជិតស្និទ្ធឡើងក្នុងសង្គម។ លើសពីនេះទៀត ជំនឿញ៉ាំងឱ្យមនុស្សដឹងបុណ្យដឹងបាប ស្គាល់សេចក្តីល្អអាក្រក់។ ក្នុងវប្បធម៌នីមួយៗ មនុស្សតែងមានទស្សនវិជ្ជាដែលជាប្រដាប់សម្រាប់សញ្ជឹងគិត ហើយទស្សនវិជ្ជាមានទាក់ទងក្នុងវប្បធម៌នីមួយៗនោះ។

ទស្សនៈខ្មែរយើងចំពោះជំនឿនេះមានដំណើរការលូតលាស់កាន់តែប្រសើរឡើងៗជាលំដាប់តាំងពីសម័យបុរេប្រវត្តិសាស្ត្រ ហ្វូណន ចេនឡា មហានគរ រហូតមកដល់សម័យបច្ចុប្បន្ន។ ខ្មែរបានសំយោគជំនឿធំៗបីគឺ ជំនឿលើព្រលឹងដូនតា ជំនឿលើព្រះពុទ្ធសាសនានិងជំនឿលើព្រហ្មញ្ញសាសនាមកជាជំនឿតែមួយគឺជំនឿសាសនាដើមរបស់ខ្មែរម្ចាស់ស្រុក។

**-ជំនឿលើអ្នកតា**

ជំនឿលើអ្នកតានេះមានប្រវត្តិតាំងពីយូរយារណាស់មកហើយ តាំងពីប្រទេសយើងពុំទាន់បានបង្កើតរដ្ឋទៅទៀត ពោលគឺមុនពេលមានវត្តមានព្រះថោង នាងនាគ ឬហ៊ុនទៀន លីវយី ពោលគឺមុនមានឥទ្ធិពលឥណ្ឌា និងចិនចូលមកក្នុងទឹកដីកម្ពុជា។ អ្នកតាមាននៅពាសពេញគ្រប់ទីកន្លែងតាមជំនឿរបស់ម្ចាស់ស្រុក។ ប្រភពអ្នកតាទាំងអស់នោះមានលក្ខណៈខុសៗគ្នា។ អ្នកតាខ្លះមានប្រភពដើមមកពីតួអង្គប្រវត្តិសាស្ត្រ ខ្លះទៀតមានប្រភពពីបុគ្គលដែលមានមហិទ្ធិឫទ្ធិកាលពីអ្នកនោះនៅមានអាយុជីវិត។

ដូច្នេះ យើងត្រូវថែរក្សាទុកបន្តទៀតនូវចំណុចណាមានប្រយោជន៍ ត្រូវចម្លងទុកជាកស្តុតាងនូវមរតកល្អដែលយើងមានគឺតម្លៃ

---

[៨] *សមាគម សម្តេច ជួន ណាត ៖ **ច្បាប់ផ្សេងៗ** ដ.៦.ម.*

វប្បធម៌ អរិយធម៌បុរាណរបស់ជាតិយើង ឬជាប្រវត្តិសាស្ត្រសម្រាប់ទុកឱ្យមនុស្សខ្មែរជំនាន់ក្រោយបានដឹងអំពីជំនឿទំនៀមទម្លាប់ ប្រពៃណី និងទស្សនវិជ្ជាដើមរបស់ខ្លួន។ ម៉្យាងទៀត យើងក៏ត្រូវរកមធ្យោបាយកម្ចាត់ចោលជាបណ្ដើរៗ ចំណុចណាចាស់គម្រិលហួសហេតុពេក ឬវាឆ្ងាយចាកពីការពិតពេកដែលធ្វើឱ្យអសកម្មក្នុងការអភិវឌ្ឍជាតិ។

**-ជំនឿលើមេបា**

ប្រវត្តិទស្សនៈមេបាមួយចំនួនក្នុងសង្គមខ្មែរ គឺផ្ដើមចេញពីពាក្យម្ដាយ (នាងនាគ) ជាម្ចាស់ស្រុករួមផ្សំជាមួយអ្នកចំណូលស្រុក (ព្រះថោង) បង្កើតបានជាពូជវង្សខ្មែរដំបូងគេ គឺព្រះថោង នាងនាគហើយបាននាំគ្នាបង្កើតនូវទស្សនៈថ្មីមួយ គឺតួនាទីចម្បងរបស់ស្ត្រីឬម្ដាយក្នុងសង្គមខ្មែរដូចជាមាតុភូមិ មាតុប្រទេស មាតាបិតា ជីដូនជីតា មេបា មេដឹកនាំ មេស្រុក មេភូមិ...។ល។ តាមទស្សនៈនេះយើងឱ្យតម្លៃម្ចាស់ស្រុកគឺស្ដេចនាគ មហេសី និងបុត្រី។ ចំណែកឯព្រះថោងជាអ្នកចំណូលថ្មី ត្រូវតែគោរពប្រតិបត្តិ និងយល់ព្រមជាមួយអនាគតមាតាបិតាក្មេក និង មហេសី។ មេបាគឺជាកន្សោមពាក្យសម្រាប់ប្រើរវាងម្ខាងជាភេទស្ត្រី (មេ) និងម្ខាងទៀតជាភេទប្រុស (បា) ដែលមានន័យថាម្ដាយឪពុកឬមាតាបិតា។ ការវិវត្តន័យនៃពាក្យនេះមាន លក្ខណៈឃ្លាតឆ្ងាយពីន័យដើមបន្តិច គឺសំដៅលើមនុស្សណាដែលជាប្រធានក្នុងការនិយាយកិច្ចការផ្សេងៗ ជាពិសេសទាក់ទងនឹងការស្ដីដណ្ដឹងកូនក្រមុំ និងក្នុងការរៀបអាពាហ៍ពិពាហ៍កូនប្រុស កូនស្រី។ មេបានៅទីនេះគឺមិនសំដៅតែលើស្ត្រី និងបុរសដែលបង្កើតនិងចិញ្ចឹមកូនស្រី កូនប្រុស នៃពិធីមង្គលការនោះទេ គឺអាចជាអ្នកតំណាងក៏បានដែរ។ ន័យនៃពាក្យមេបាមួយទៀត គឺសំដៅលើដូនជីបួនសែស្រឡាយនៃបុគ្គលដែលបានស្លាប់ទៅហើយ។ សែស្រឡាយនេះ គេនិយាយថា ៧ សន្ដាន គឺរាប់ពីជីដូនជីតាទួតរហូតដល់ចៅទួត។ បើកាលណាមាននរណាម្នាក់មានជំងឺឬមានបញ្ហាអ្វីមួយក្នុងត្រកូលគ្រួសារនោះ គេថាខុសមេបា ខុសចាស់ទុំ ឬខុសដូនជីបួន។

តាមជំនឿខ្មែរ ការខុសឆ្គងចំពោះមេបាមានបីបែប៖ ខុសមេបាចាស់ទុំ ខុសមេបាកំលោះក្រមុំ និងខុសមេបាផ្កាប់មុខ។

• ***ខុសមេបាចាស់ទុំ*** ៖ គឺក្រុមញាតិបងប្អូនប្រាំពីរសណ្ដានទាស់ទាញខ្វែងគំនិតគ្នា ដែលសីលធម៌មេបាហាមឃាត់។ នៅពេលដែលគ្រួសារទាស់ទែងរាំងមាត់កគ្នា មេបាប្រកាន់ហើយធ្វើឱ្យសមាជិកក្នុងគ្រួសារណាមួយឈឺ។ បើមានខុសឆ្គងមេបាចាស់ទុំបែបនេះ គេត្រូវប្រមូលបងប្អូនចាស់ទុំក្នុងញាតិប្រាំពីរសន្ដាន ពិសេសអ្នកឈ្លោះប្រកែក រាំងមាត់នឹងគ្នា មកផ្ទះគ្រួសារអ្នកជំងឺ សែនព្រេនថ្វាយតង្វាយ ម្លូស្លា អុជទៀនធូបដើម្បីអង្វរករមេបាសុំឱ្យឈប់ប្រកាន់ខឹងនឹងកូនចៅ

តទៅទៀត។ យើងខ្ញុំជាកូនចៅសន្យាថានឹងឈប់ឈ្លោះទាស់ទែងខ្វែងគំនិតគ្នាតទៅទៀតហើយ។ សូមលោកមេបាដកពិសពរពីអ្នកជំងឺឱ្យជាសះស្បើយចាប់ពីពេលនេះតទៅ។

•***ខុសមេបាកំលោះក្រមុំ៖*** មេបាកំលោះក្រមុំ គឺទាក់ទងដល់ព្រលឹងអ្នកដែលបានស្លាប់ទៅហើយនៅមានការកិច្ចថែទាំកូនចៅជាក្រមុំ កំលោះជាពិសេសអ្នកដែលមានវ័យពេញក្រមុំ។ ឥទ្ធិពលនៃរបបមាតាធិបតេយ្យគឺមិនត្រឹមតែជះឥទ្ធិពលដល់មនុស្សស្រីក្នុងគ្រួសារ សង្គម និងការដឹកនាំនោះទេ ប៉ុន្តែថែមទាំងជះឥទ្ធិពលដល់ប្រពៃណីទំនៀមទម្លាប់ទៀតផង ជាពិសេសបានក្លាយជាជំនឿមួយជួយបំភ័យដល់ស្រីពេញវ័យឱ្យចេះអៀនខ្មាសមិនជ្រួលច្របល់តាមតណ្ហាអូសទាញ ឬដោយពោយតាមការលួងលោមរបស់បុរសៗ។ តាមផ្នត់គំនិតក្នុងសង្គមខ្មែរគេជឿថាកូនស្រី គឺជាសិរីសួស្តីក្នុងគ្រួសារនាំមកនូវសុភមង្គល ភាពថ្កុំថ្កើងដល់សៃស្រឡាយនិងគ្រួសារ។ បើកូនស្រីលួចមានសហាយស្មន់ លួចលាក់មានប្រុសទុំមុនស្រគាល ដោយឪពុកម្តាយនិងក្រុមគ្រួសារមិនបានដឹងមិនបានទទួលស្គាល់ កូនស្រីនោះនឹងក្លាយជាអ្នកបំផ្លាញកេរ្តិ៍ឈ្មោះក្នុងគ្រួសារទៅវិញ ហើយគេបានប្រៀបប្រដូច នឹងប្រហុកមួយពាងក្នុងផ្ទះដែលបញ្ចេញក្លិនអសោចដល់អ្នកជិតខាងផងដែរ។

•***ខុសមេបាផ្កាប់មុខ៖*** សំដៅសកម្មភាពផិតក្បត់នឹងប្តី ទៅមានសហាយ ស្មន់អន្ទករ។ ការខុសមេបាផ្កាប់មុខនេះជាការលំបាកស្វែងរកអ្នកប្រព្រឹត្តណាស់។

នៅក្នុងទំនៀមទម្លាប់និងជំនឿខ្មែរ ច្បាប់មេបាបានឱ្យតម្លៃខ្ពស់ទៅលើនារី (នារីត្រូវមានសីលធម៌ខ្ពស់ជាងបុរស) គេត្រូវហាត់ពត់លត់ដំចិត្ត និងខិតខំបង្កើនសីលធម៌ពិសេសមួយសម្រាប់យុវជន (ពិសេសនារី)។ នារីដែលខុសនឹងសីលធម៌ ដូចជាការលួចលាក់រួមរ័កស្នេហាគ្នាដោយមិនឱ្យចាស់ទុំដឹង ផិតប្តីរបស់ខ្លួនទៅមានសាហាយស្មន់នោះ បានធ្វើឱ្យកិត្តយសផ្ទាល់ខ្លួននិងគ្រួសារធ្លាក់ចុះដល់បាតាល[៩]។ ផលវិបាករបស់មនុស្សដែលមានកំហុសមេបាផ្តល់ផលវិបាកដល់គ្រួសារនិងកូនចៅក្រោយៗទៀត ដោយគេយល់ថា **ម៉ែឪវាយ៉ាងម៉េចកូនវាយ៉ាងនោះដែរ** ទោះជាកូននោះមានរូបសម្បត្តិនិងចរិយាសម្បត្តិល្អប្រពៃយ៉ាងណាក៏ដោយ។ ផលវិបាកដ៏ធ្ងន់មួយទៀត គឺសង្គមមិនឱ្យតម្លៃ អ្នកដែលអត់ខាន់ស្លាទេ។

ដូច្នេះ ជំនឿមេបាជាបន្ទាត់សីលធម៌ល្អមួយ សម្រាប់ទ្រទ្រង់សង្គមឱ្យបានល្អប្រសើរ អ្នកដែលមិនគោរពបន្ទាត់សីលធម៌នេះ ត្រូវទទួលទណ្ឌកម្មពីសង្គមទាំងផ្លូវកាយនិងផ្លូវចិត្ត។

---

[៩] បាតាល មានន័យថា ប្រទេសជាឱកាសក្រោមផែនដី, នាគពិភព ឬ ពិភពនាគ (វចនានុក្រមខ្មែរ)។

**-ជំនឿលើគ្រូ**

ជំនឿលើគ្រូនេះហាក់ដូចជាទស្សនៈអរូបី ដែលគិតថាជាសិល្ប៍ ជាមន្តអាគមដែលមានឥទ្ធិពលលើមនុស្សនិងសង្គមមនុស្ស។ ពាក្យ គ្រូ នៅទីនេះ មិនមែនសំដៅលើបុគ្គលជាអ្នកផ្តល់ចំណេះដឹងឬជាអ្នកបង្រៀននោះទេ។ ប្រភពដើមនៃពាក្យគ្រូ (Guru) មានប្រភពពីសំស្ក្រឹត នៅប្រទេសឥណ្ឌា ប្រមាណ១៥០០ឆ្នាំមុនគ.ស. ក្នុងព្រហ្មញ្ញសាសនា[10] ដែលមានប្រភពមកពីអ៊ីរ៉ង់តាមរយៈពួកអារ្យ៉ន គឺសំដៅទៅលើបុគ្គលដែលចេះចាំលទ្ធិសាសនាប្រពៃណី ឬជាអ្នកមានបទពិសោធន៍សម្រាប់ផ្តល់ឱ្យមនុស្សជំនាន់ក្រោយៗទៀត។ ទស្សនៈព្រះពុទ្ធសាសនាយល់ថា ព្រះពុទ្ធគឺជាព្រះបរមគ្រូ ដែលមានន័យថា ព្រះអង្គជាអ្នកផ្សព្វផ្សាយនូវពុទ្ធិដោយផ្ទាល់មាត់នៅគ្រប់ទីកន្លែង ជាពិសេសកន្លែងដែលព្រះអង្គទ្រង់និមន្តបិណ្ឌបាត និងផ្សព្វផ្សាយព្រះធម៌៨៤០០០ ធម្មក្ខន្ធ។[11] លោក គេង វ៉ាន់សាក់ លើកឡើងថាគ្រូមកពីគំរូនៃជំនឿខ្មែរទាំង៥គឺជំនឿលើព្រះ ជំនឿលើមេបា តានិងចៅដែលខ្មែរកំណត់បានថាជាជំនឿសំខាន់សម្រាប់អំពើល្អនិងសេចក្តីសុខក្នុងសង្គមគ្រួសារនិងសង្គមមនុស្សទាំងមូល។ ឧទាហរណ៍ ក្នុងគ្រួសារមួយ បើឪពុកម្តាយនិងសមាជិកដទៃជាគំរូល្អតាមរយៈកម្មវិធីផ្សេងៗ នោះពិតជាឥរិយាបថរបស់បុត្រាបុត្រីមិនស្ទើរជាឃ្លាតឆ្ងាយពីឥរិយាបថឪពុកម្តាយប៉ុន្មានទេ។ដូច្នេះយើងអាចសន្និដ្ឋាន ថាជំនឿលើគ្រូនេះមានលក្ខណៈជារូបីនិងអរូបី។ ជនជាតិផ្សេងៗបានសន្មតថា គ្រូគឺជាមនុស្សឬជីវចលដែលគ្មានរូបហើយមានចិត្តគំនិតទូលំទូលាយចំណេះដឹងជ្រៅជ្រះអាចជួយដោះស្រាយបញ្ហាមនុស្ស និង ផ្តល់សេចក្តីសង្ឃឹមសម្រាប់អនាគតផងដែរ។

សង្គមខ្មែរបានកំណត់ថាគ្រូសំខាន់ៗមានបី គឺគ្រូអាចារ្យ គ្រូឧបជ្ឈា និងគ្រូបាធ្យាយ ហើយគ្រូទាំងបីមានភារកិច្ចនិងកាតព្វកិច្ចខុសគ្នាក្នុងការអប់រំទាំងក្នុងសាលារៀនទាំងក្នុងសង្គមក្តី ហើយសុទ្ធតែបានរួមចំណែកកសាងធនធានមនុស្សដ៏សំខាន់ ទាំងជំនាញ សីលធម៌ សុខភាពនិងចំណេះដឹងដល់ប្រជាជនក្នុងការកសាងស្រុកទេសឱ្យក្លាយជាអាណាចក្រធំមួយក្នុងតំបន់។

•*គ្រូអាចារ្យ*៖ សំដៅទៅលើមនុស្សមានមារយាទ ចរិតលក្ខណៈល្អ មានភាពសុចរិតត្រឹមត្រូវ អ្នកប្រព្រឹត្តល្អ អ្នកដែលសិស្សត្រូវគោរព អ្នកផ្តល់ប្រយោជន៍ដល់សិស្សនិងសង្គមមនុស្សទូទៅ ពោលគឺជាអ្នកមានចំណេះដឹងតាមក្បួនតាមគម្ពីរសម្រាប់បង្រៀនអ្នកដទៃ។

[10] ហែម ឡាច៖ **ជំនឿសាសនាដើមរបស់ខ្មែរម្ចាស់ស្រុក** *និក្ខេបបទបណ្ឌិតទស្សនវិជ្ជា* រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៧

[11] **ជំនឿសាសនាដើមរបស់ខ្មែរម្ចាស់ស្រុក** .ដ.

ប្រទេសណាក៏ដោយ កាលណាធនធានមនុស្សខាងគ្រូអាចារ្យនេះធ្លាក់ចុះ វាជាសញ្ញាអវិជ្ជមានមួយដែលបញ្ជាក់ថាស្ថានភាពស្រុកទេសមានវិបត្តិខាងសីលធម៌ សង្គម សាសនា និងអាចឈានដល់គ្រោះមហន្តរាយប្រទេសជាតិជាមិនខាន។ ដូច្នេះ ប្រទេសនីមួយៗគេតែងតែយកចិត្តទុកដាក់ជាអាទិភាពខាងធនធានគ្រូអាចារ្យនេះទោះក្នុងស្ថានភាពណាក៏ដោយ។

•***គ្រូឧបជ្ឈា៖*** គឺជាគ្រូបង្រៀនខាងសីលធម៌ អ្នកបង្រៀនខាងច្បាប់សាសនាព្រះពុទ្ធ និងសម្រាប់ត្រួតពិនិត្យទូន្មានប្រៀនប្រដៅដល់មនុស្សជំនាន់ក្រោយ។ តួនាទីគ្រូឧបជ្ឈា គឺសម្រាប់ពិនិត្យពិច័យលើបុគ្គលិកលក្ខណៈសម្បត្តិរបស់ព្រះភិក្ខុ និងសាមណេរឱ្យក្លាយជាព្រះសាវ័កដ៏ល្អរបស់ព្រះបរមគ្រូ ជាធនធានសម្រាប់ទ្រទ្រង់នូវលទ្ធិព្រះពុទ្ធសាសនាឱ្យបានរុងរឿងគង់វង្ស។

•***គ្រូបាធ្យាយ៖*** គឺសំដៅលើសែស្រឡាយអំបូរជួរពូជខ្សែខាងម្ដាយឬខាងឪពុក។ ជំនឿលើ គ្រូបាធ្យាយនេះគឺជាទស្សនៈ បែបអរូបីមួយ ដែលអាចមានប្រភពពីជំនឿលើព្រលឹងរបស់ខ្មែរក្នុងសម័យបុរេប្រវត្តិ ប៉ុន្តែជំនឿនេះមានលក្ខណៈចង្អៀតជាង ព្រោះសំដៅទៅលើព្រលឹងខាងឪពុកនិងខាងម្ដាយដែលមានភារកិច្ចថែទាំកូនចៅញាតិសន្តាន ក្នុងគ្រួសារឱ្យបានសេចក្ដីសុខក្សេមក្សាន្តនិងគង់វង្ស។ គេជឿថា មនុស្សគ្រប់រូបដែលរស់រានមានជីវិតគឺសុទ្ធតែមានគ្រូបាធ្យាយតាមថែទាំ និងមើលការខុសត្រូវការពារពីសត្រូវគ្រប់ប្រភេទ ជាពិសេសគឺជាអ្នកចង្អុលប្រាប់ពីគ្រោះកាចគ្រោះភ័យដែលនឹងកើតមានឡើងដល់បុគ្គលដែលជាសមាជិកនោះទៀតផង ហើយក៏តម្រូវឱ្យបុគ្គលនោះមានការនឹកគុណសងគុណដល់គ្រូបាធ្យាយវិញដែរតាមរយៈការរៀបចំសំណែន និងការរៀបចំអាសនៈ ជាបាយសីតាមជាន់ថ្នាក់ទៅតាមជំនឿនៃក្រុមគ្រួសារ។ គ្រួសារខ្មែរនីមួយៗតែងតែមានមនុស្សម្នាក់ក្នុងគ្រួសារជាអ្នកស្នងរូបនៃគ្រូបាធ្យាយនេះ ហើយក៏ជាអ្នកមើលការខុសត្រូវនូវរាល់សកម្មភាពទាំងឡាយក្នុងគ្រួសារ។[12]

ជាទូទៅមាតាបិតា គេតែងតែចាត់ទុកជាព្រះកន្ទោងគឺជាធំ (សរសរកន្ទោង) សរសេរកណ្ដាលឬសរសរទ្រូង។ ព្រះកន្ទោងនេះមានភារកិច្ចសំខាន់ណាស់ក្នុងការថែរក្សាទ្រព្យសម្បត្តិ អប់រំកូនចៅប្រុសស្រីឱ្យមានចំណេះដឹងខាងផ្លូវលោក ផ្លូវធម៌ សីលធម៌រស់នៅប្រចាំថ្ងៃ មានសុខភាពមាំមួននិងអនាគតភ្លឺស្វាង។ គេអាចនិយាយបានថាព្រះកន្ទោងនេះគឺជាព្រះរស់ព្រះផ្ដល់កំណើត ព្រះថែទាំ ព្រះផ្ដល់សក្តិ ព្រះផ្ដល់យសក្នុងគ្រួសារក៏ដូចជាក្នុងសង្គម។ ឪពុកម្ដាយទាំងឡាយ

---

[12] ហែម ឡាចៈ ***ជំនឿសាសនាដើមរបស់ខ្មែរម្ចាស់ស្រុក*** ដ.ឯ.ម.

តែងតែ មានកាតព្វកិច្ច៥យ៉ាងចំពោះកូនគឺ ផ្តល់កំណើត ចិញ្ចឹមជីវិត ផ្តល់ការរៀនសូត្រ ផ្តល់កេរមរតក និង រៀបចំមង្គលការ។ ក្នុងពិធីមង្គលការ ជាពិសេសពិធីកាត់ខាន់ស្លាក៏មានការរៀបរាប់រំលឹកឡើងវិញអំពីគុណម្តាយនិងឪពុកក្នុងការតស៊ូចិញ្ចឹមបីបាច់ថែរក្សាកូនស្រី កូនប្រុស រហូតដល់ធំពេញវ័យមានចរិយាសម្បត្តិ និងរូបសម្បត្តិល្អ ហើយរៀបមង្គលការចំពោះមុខមាតាបិតា។ ចំណែកឯផ្កាស្លា ដែលគេយកមកប្រើក្នុងពិធីនេះចែកជា៣ផ្នែកគឺធាតុខាងឪពុក២១ ធាតុខាងម្តាយ ១២ និងបងប្រុស៦ (តាមទម្រង់អាពាហ៍ពិពាហ៍ខ្មែរ)។ ធាតុដែលសំខាន់បំផុតគឺធាតុឪពុកនិងធាតុម្តាយជាគុណដ៏ធំធេងណាស់សម្រាប់កូនស្រី កូនប្រុសនៅក្នុងពិធីអាពាហ៍ពិពាហ៍នេះ។

ដូច្នេះ ជំនឿលើគ្រូបាធ្យាយនេះ ទោះបីមានលក្ខណៈជារូបីក្តី អរូបីក្តី ក៏សុទ្ធតែបង្ហាញពីគុណសម្បត្តិក្នុងគ្រួសារតាមជួយថែរក្សាការពារ ជួយចិញ្ចឹមជីវិតនិងប្រៀនប្រដៅកូនចៅឱ្យក្លាយជាមនុស្សល្អក្នុងសង្គម។

បុព្វការីខ្មែរ តែងតែអប់រំទូន្មានប្រៀនប្រដៅកូនចៅឱ្យយកចិត្តទុកដាក់ខ្ពស់ ចំពោះគ្រូអាចារ្យ គ្រូឧបជ្ឈានិងគ្រូបាធ្យាយរបស់ខ្លួន។ លោកចាត់ទុកជាសីលធម៌ដ៏ឧត្តុង្គឧត្តមមួយរបស់សិស្សគណជាទូទៅ។ លោកតែងតែពន្យល់ថា អ្នកដែលមានជំនឿជឿជាក់ដឹងគុណ តបគុណចំពោះគ្រូមិនច្យុតិឡើយ។

ជំនឿរបស់ខ្មែរដែលមានតាំងពីបុរាណកាលមកនោះ បានក្លាយជា អត្តសញ្ញាណវប្បធម៌មួយដែលកំពុងតែមានឥទ្ធិពលក្នុងពេលបច្ចុប្បន្ន។ ជំនឿទាំងអស់នេះមានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាអត្តសញ្ញាណជាតិសាសន៍ខ្មែរ។ ទោះបីជំនឿទាំងអស់នេះមានទិដ្ឋភាពខុសៗគ្នាក៏ពិតមែន តែគេសង្កេតឃើញថាវាមានលក្ខណៈជាការដឹងគុណ ការសងគុណ និងការរក្សាមរតកស្នាដៃរបស់មនុស្សជំនាន់មុន។ ក្រៅពីនេះ ជំនឿទាំងអស់នោះមានលក្ខណៈជាការសំយោគរវាងទ្រឹស្តីទេវៈ និងទ្រឹស្តីជំនឿផ្សេងៗដែលគ្មានអ្វីក្រៅពីការសុំសេចក្តីសុខ ការសាមគ្គីជាកម្លាំងមួយរវាងនិន្នាការជំនឿ ដើម្បីកសាងប្រទេសឱ្យបានរីកចម្រើន។ ដូច្នេះ ទស្សនវិជ្ជានេះបានជំរុញឱ្យមនុស្សជំនាន់ថ្មីខិតខំកសាងទុកនូវស្នាដៃតូចក្តី ធំក្តី ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ចាប់ពីក្នុងគ្រួសារ ស្ថាប័ន រហូតដល់ក្នុងសង្គមជាតិ។ សមិទ្ធផលទាំងអស់នេះបានក្លាយជាសោភណភាពមួយរបស់ស្រុកទេស និងជាទីតាំងទេសចរណ៍ដូចជា រូបសំណាកអ្នកតាដំបងក្រញូងនៅខេត្តបាត់ដំបង អ្នកតាឃ្លាំងមឿងនៅខេត្តពោធិ៍សាត់ លោកតាខ្មៅនៅក្រុងតាខ្មៅ ខេត្តកណ្តាល លោកយាយម៉ៅ នៅពេជ្រនិល លោកយាយពេញ នៅវត្តភ្នំ រូបសំណាកព្រះបាទជ័យវរ្ម័នទី៧ កវីក្រមង៉ុយ សម្តេចព្រះសង្ឃរាជ ជួន ណាត ជាដើម។

## សន្និដ្ឋាន

សរុបសេចក្តីមក ប្រទេសកម្ពុជាយើងមានពន្លកទស្សនវិជ្ជាតាំងពីរយូរលង់ណាស់មកហើយ ហើយបានលេចត្រដែតឡើងចាប់ពីសម័យនគរភ្នំ សម័យចេនឡា ជាពិសេសនៅសម័យអង្គរ (សម័យមហានគរ)។ ទស្សនវិជ្ជាខ្មែរត្រូវបានកប់ទុកក្នុងជំនឿ សិលាចារឹក បទចម្រៀង កំណាព្យ សុភាសិត សិល្បៈអក្សរសិល្ប៍ ។ល។ ដែលបញ្ជាក់ឱ្យឃើញថា ខ្មែរមានទស្សនៈជ្រៅជ្រះរបស់ខ្លួនក្នុងការរួមចំណែកកសាងនិងការពារមាតុភូមិ។ បទចម្រៀង "**ពង្សាវតារខ្មែរ**" ដែលជាព្រះរាជនិពន្ធដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ក៏បង្កប់នូវទស្សនវិជ្ជាមកបញ្ជាក់ផងដែរ (ខ្មែររុងរឿងដោយខ្មែរមានទស្សនវិជ្ជា) និងវិស័យអាទិភាពជាច្រើនទៀត។ ប៉ុន្តែ នៅពេលដែលខ្មែរបែកបាក់គ្នា និងមានការឈ្លានពានពីសត្រូវគ្រប់ទិសទី ខ្មែរបានកសាងទស្សនវិជ្ជារបស់ខ្លួនមានលក្ខណៈទុទិដ្ឋិនិយមហួសហេតុ ផ្អែកលើជំនឿ ងងឹតងងល់ ផ្អែកលើព្រេងវាសនាជាធំ និងផ្អែកលើកម្មពៀរពីអតីតជាតិ។ ចំណែកឯប្រព័ន្ធទស្សនវិជ្ជាជ្រៅជ្រះមានលក្ខណៈតស៊ូប្រយុទ្ធនឹងសត្រូវ ត្រូវបានបំភ្លេចចោល។ ខ្មែរមួយចំនួនមានជំនឿងងឹតងងល់ ខ្វះការពិចារណារកហេតុផលដែលនាំឱ្យខ្មែរបាត់បង់ទឹកដី និងទ្រព្យធនរបស់ជាតិអស់ជាច្រើន។

ម៉្យាងទៀតខ្មែរមួយចំនួនមិនស្រឡាញ់ទស្សនវិជ្ជា មិនព្រមសិក្សាទស្សនវិជ្ជា រហូតដល់យល់ថា ទស្សនវិជ្ជាមានលក្ខណៈអរូបីហួសហេតុ ពិបាកយល់ ពិបាកសិក្សា ពិបាកយកទៅអនុវត្ត ឬអនុវត្តមិនបាន ហើយក៏បោះបង់ចោលមុខវិជ្ជានេះទៅ។ ឥរិយាបថអវិជ្ជមានទាំងនេះបណ្តាលមកពីការភាន់ច្រឡំ ឬការយល់ដឹងអំពីទស្សនវិជ្ជាមិនបានស៊ីជម្រៅ។ ការបោះបង់ចោលមុខវិជ្ជាទស្សនវិជ្ជាហាក់បីដូចជាការសម្លាប់ស្មារតីមនុស្ស។ កម្មវិធីសិក្សាខ្វះទស្សនវិជ្ជា ជាកម្មវិធីសិក្សាមួយដែលមិនទាន់គ្រប់ជ្រុងជ្រោយ ព្រោះអាចខ្វះការត្រិះរិះពិចារណាហ្មត់ចត់និងនាំឱ្យតម្លៃសីលធម៌ធ្លាក់ចុះ៕

## ឯកសារពិគ្រោះ

១-ជា គឹមនេង និង ហ៊ិន សំអាត៖ *រដ្ឋបាលសាធារណៈ* ឆ្នាំ២០២១

២-ជួន ណាត៖ ***វចនានុក្រមខ្មែរ*** ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧

៣-ឈត ប៊ុនថង៖ ***ទស្សនវិជ្ជាខ្មែរតាមរយៈសុភាសិត*** ភាគទី១ ឆ្នាំ២០២២

៤-ត្រឹង ង៉ា៖ ***អរិយធម៌ខ្មែរ*** ការផ្សាយរបស់អ្នកនិពន្ធ គ.ស. ១៩៧៥

៥-សមាគម សម្តេច ជួន ណាត៖ ***ច្បាប់ផ្សេងៗ*** ភ្នំពេញ ព.ស. ២៥១៨

៦-ហែម ឡាច៖ **ជំនឿសាសនាដើមរបស់ខ្មែរម្ចាស់ស្រុក** និក្ខេបបទបណ្ឌិតទស្សនវិជ្ជា រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៧

៧-ឡុង សៀម «*ស្ថាននាមវិទ្យាខ្មែរ* Toponymie Khmer» ពុទ្ធសាសនបណ្ឌិត្យ ១៩៩៧។

៨-អ្នកព្រះកិរម្យភាសា អ៊ូ ហៅ ង៉ុយ៖ ***បណ្ដាំក្រមង៉ុយ*** ការផ្សាយរបស់អង្គការសន្តិស្ម័គ្រចិត្តកម្ពុជា គ.ស. ២០០៥។